អបអរសាទរខួប១៥ឆ្នាំ

នៃការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

៧ កក្កដា ២០០៨ - ៧ កក្កដា ២០២៣

# កម្រងសមិទ្ធិផលការងារសំខាន់ៗ
# នៅរមណីយដ្ឋានប្រាសាទព្រះវិហារ

រៀបចំដោយ អាជ្ញាធរជាតិព្រះវិហារ

2023

អបអរសាទរខួប១៥ឆ្នាំ
នៃការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក
៧ កក្កដា ២០០៨ - ៧ កក្កដា ២០២៣

# កម្រងសមិទ្ធផលការងារសំខាន់ៗ នៅរមណីយដ្ឋានប្រាសាទព្រះវិហារ

ក្រុមការងារខ្លឹមសារ ៖
គឹម សំណាង, អ៊ា ដារិទ្ធ, ភិន សំណាង, តូច បន្ទ័របតា, ឋូ ឋុន និង ឈាង ពិសាល
ក្រុមការងារបច្ចេកទេស ៖
គឹម សំណាង, ឧត្តម វឌ្ឍនៈ, ណុប វ៉ាន់សិទ្ធ
ត្រួតពិនិត្យ ៖
ឯកឧត្តម គង់ ពុទ្ធិការ

អាជ្ញាធរជាតិព្រះវិហារ
2023

# មាតិកា


អាជ្ញាធរជាតិព្រះវិហារ ........ 3

១. ការងារចុះបញ្ជីបុរាណដ្ឋាន និងវត្ថុសិល្បៈ

- ការងារចុះបញ្ជីបុរាណដ្ឋាន ........ 12
- ការងារចុះបញ្ជីវត្ថុសិល្បៈនៅប្រាសាទព្រះវិហារ ........ 13
- ការងារចុះបញ្ជីវត្ថុសិល្បៈនៅប្រាសាទតូច ........ 13
- កម្មវិធីអប់រំផ្សព្វផ្សាយបេតិកភណ្ឌ ........ 14

២. ការងារកំណាយស្រាវជ្រាវ

- ការងារកំណាយស្រាវជ្រាវប្រព័ន្ធរំដោះទឹកភ្លៀង ........ 18
- ការងារកំណាយស្រាវជ្រាវ និងស្ដារឡើងវិញបារាយណ៍ខាងលិចនិងខាងកើត ........ 19
- ការងារកំណាយស្រាវជ្រាវលិង្គព្រះឥសូរ ........ 20

៣. ការងាររៀបចំផែនទីហានិភ័យ

- ការងារចងក្រងផែនទីហានិភ័យរចនាសម្ព័ន្ធប្រាសាទព្រះវិហារ ........ 24

៤. ការងាររអភិរក្ស

- ការងារទប់ទ្រហេដ្ឋារចនាសម្ព័ន្ធប្រាសាទព្រះវិហារ ........ 28
- ការងារសាងសង់ជណ្ដើរនិងកម្រាលឈើ និងរៀបចំសណ្ដាប់ធ្នាប់ថ្ម ........ 29

## ៥. ការងារជួសជុល


- គម្រោងជួសជុល និងអភិរក្សជណ្តើរខាងជើង ........ 32
- គម្រោងជួសជុល និងអភិរក្សគោបុរៈទី៥ ........ 34
- គម្រោងជួសជុលនិងអភិរក្សគោបុរៈទី១ ដល់ទី៣ ........ 35
- ការងារជួសជុលនិងអភិរក្សស្ពានហាល បង្គោលផ្កាឈូក និងបង្កាន់ដៃនាគ ........ 36
- វគ្គបណ្តុះបណ្តាលជំនាញអភិរក្ស និងជួសជុលវត្ថុបុរាណ ........ 37


## ៤. ការងារបរិស្ថាន និងព្រៃឈើ


- ការងារអភិរក្ស និងស្តារគម្របព្រៃឈើឡើងវិញនៅតំបន់ប្រាសាទព្រះវិហារ ........ 40


## ៥. ការងារអភិវឌ្ឍន៍សហគមន៍


- ការងារបណ្តុះបណ្តាលបច្ចេកទេស និងបង្កើនសមត្ថភាពកសិករគំរូ ........ 44
- ការងាររៀបចំកសិដ្ឋានបិញ្ចឹមត្រីទីឡាព្យា ........ 45
- ការងារលើកកម្ពស់សុវត្ថិភាពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ........ 46
- ការងារស្ទួនបន្លែសវីរាង្គភូមិធម្មជាតិសម្តេចតេជោរបស់អាជ្ញាធរជាតិព្រះវិហារ ........ 47


## ៦. ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ


- សារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ ........ 50
- ការងាររៀបចំស្ថាបនាមណ្ឌលអគារបដិសណ្ឋារកិច្ចប្រាសាទព្រះវិហារ ........ 51
- ការងាររៀបចំស្ថាបនាផ្លូវបេតុងលើភ្នំប្រាសាទព្រះវិហារ ........ 52
- ការងាររៀបចំស្ថាបនាជណ្តើរឈើអមជណ្តើរបុរាណខាងកើតភ្នំប្រាសាទព្រះវិហារ ........ 53

# អាជ្ញាធរជាតិព្រះវិហារ



# អាជ្ញាធរជាតិព្រះវិហារ

អាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ ធម្មជាតិតំបន់ព្រះវិហារ ឬហៅកាត់ថា “អាជ្ញាធរជាតិព្រះវិហារ” ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៦ ហើយក្រោយមកបានក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅឆ្នាំ២០២០ ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អាជ្ញាធរជាតិព្រះវិហារមាននាយកដ្ឋានចំណុះចំនួន ៧ ៖ (១) នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញកិច្ច (២) នាយកដ្ឋាន អភិរក្សនិងបុរាណវិទ្យា (៣) នាយកដ្ឋាន អភិវឌ្ឍន៍ទេសចរណ៍ (៤) នាយកដ្ឋាន គ្រប់គ្រងដីធ្លី នគរូបនីយកម្ម និងអភិវឌ្ឍន៍សហគមន៍ (៥) នាយកដ្ឋាន បរិស្ថាន ព្រៃឈើ និងទឹក (៦) នាយកដ្ឋាន ស្រាវជ្រាវ បណ្តុះបណ្តាល និងតម្កល់ឯកសារ និង(៧) នាយកដ្ឋាន សណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ។

បេសកកម្មចម្បងរបស់អាជ្ញាធរជាតិព្រះវិហារ គឺបំពេញមុខងារជាសេនាធិការឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈលើបេសកកម្មការពារ ថែរក្សា អភិរក្សគ្រប់គ្រងនិងលើកតម្លៃបុរាណវិទ្យា វប្បធម៌ បរិស្ថាន និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ ព្រមទាំងរមណីយដ្ឋានមួយចំនួនទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិព្រះវិហារ។ លើសពីនេះ អាជ្ញាធរជាតិព្រះវិហារមានភារៈកិច្ចសិក្សាស្រាវជ្រាវ រៀបចំ និងគ្រប់គ្រងធនធានធម្មជាតិ ដើម្បីអភិវឌ្ឍប្រកប ដោយចីរភាព និងរក្សាតុល្យភាពបរិស្ថាន ទឹក ព្រៃឈើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទឹកបុរាណ ផ្លូវបុរាណ និងបេតិកភណ្ឌ ដែលស្ថិតនៅក្នុងរមណីយដ្ឋានទាំងពីរឲ្យប្រកបដោយចីរភាព។

2020- បច្ចុប្បន្ន



លោកជំទាវបណ្ឌិតសភាចារ្យ
*ភឿង សកុណា*
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
ប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិព្រះវិហារ



ឯកឧត្តម *គង់ ពុទ្ធិការ*
អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ

2015-2020



ឯកឧត្តម *គឹម សេដារា*
ប្រធានអាជ្ញាធរជាតិព្រះវិហារ
និងប្រធានក្រុមប្រឹក្សាភិបាល



ឯកឧត្តម *អ៊ុក តុបបុត្រា*
អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ

2009-2015



ឯកឧត្តម *ផុច ភឿន*
ប្រធានអាជ្ញាធរជាតិព្រះវិហារ
និងប្រធានក្រុមប្រឹក្សាភិបាល



ឯកឧត្តម *ហង់ សុត*
អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ

2006-2009



ឯកឧត្តម *ទី យ៉ាវ*
ប្រធានអាជ្ញាធរជាតិព្រះវិហារ
និងប្រធានក្រុមប្រឹក្សាភិបាល



Souvenirs TRN (1962-1963).

Preah Vihear.

PELERINAGE NATIONAL A PREAH VIHEAR

LE 4 JANVIER 1962 LE PRINCE NORODOM SIHANOUK CHEF D'ETAT DU CAMBODGE PRENAIT LA TETE D'UN GRAND PELERINAGE AU SANCTUAIRE NATIONAL RECOUVRE.







ព្រះរាជដំណើរទស្សនកិច្ចរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ» នៅឆ្នាំ១៩៦២-៦៣



ទស្សនកិច្ចរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន នៅប្រាសាទព្រះវិហារនៅឆ្នាំ ២០១០-២០១១



សម្តេចតេជោនាយករដ្ឋមន្ត្រីចុះហត្ថលេខាលើឯកសារសារមន្ទីរ




ទស្សនកិច្ចរបស់សម្តេចវិបុលបញ្ញា សុខ អាន និងប្រតិភូបរទេស



ទស្សនកិច្ចរបស់លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីត្រួតពិនិត្យការងារនៅប្រាសាទព្រះវិហារ





សកម្មភាពសម្ពោធសារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ



ទស្សនកិច្ចរបស់លោក Joseph Yai និងអ្នកជំនាញការយូណេស្កូនៅឆ្នាំ២០០៨-២០០៩



សកម្មភាពដំណើរទស្សនកិច្ចអ្នកជំនាញការអន្តរជាតិនៅប្រាសាទព្រះវិហារ












សកម្មភាពអបអរសាទរការចុះប្រាសាទព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោក នាថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ នៅរាជធានីភ្នំពេញ



កិច្ចប្រជុំ ICC-Preah Vihear


សហប្រធានកិច្ចប្រជុំ ចិន - ឥណ្ឌា





# ការងារចុះបញ្ជីបុរាណដ្ឋាន
# និងវត្ថុសិល្បៈ

# ការងារចុះបញ្ជីបុរាណដ្ឋាន

ចាប់ពីឆ្នាំ២០០៨រហូតមក អាជ្ញាធរជាតិព្រះវិហារ បានរកឃើញ និងចុះបញ្ជីបុរាណដ្ឋានក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារសរុបចំនួន ៥៦ទីតាំង ក្នុងនោះមានប្រាសាទចំនួន៧ និងគ្រឹះបុរាណចំនួន៤ បារាយណ៍ចំនួន៤ ត្រពាំង និងស្រះចំនួន២២និងសហគមន៍បុរាណចំនួន ១៩កន្លែង។

ស្ថានីយបុរាណវិទ្យាក្នុងតំបន់ការពាររមណីយដ្ឋានប្រាសាទព្រះវិហារ










## ការងារចុះបញ្ជីវត្ថុសិល្បៈនៅប្រាសាទព្រះវិហារ

អាជ្ញាធរជាតិព្រះវិហារបានចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈនៅប្រាសាទព្រះវិហារបានចំនួនសរុប១០៨ ក្នុងនោះមានបម្លាក់តោចំនួន៩៤បំណែក ទេវរូបចំនួន២បំណែក ជើងទម្របដិមាចំនួន៩ដុំ និងជើងទម្រព្រះសិវលិង្គចំនួន៣ដុំ។





## ការងារចុះបញ្ជីវត្ថុសិល្បៈនៅប្រាសាទតូច

អាជ្ញាធរជាតិព្រះវិហារបានចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈ ចំនួន១៣បំណែក នៅប្រាសាទតូច ដែលស្ថិតនៅចម្ងាយ៣០០ម៉ែត្រ ភាគខាងត្បូងបារាយណ៍ខាងលិច និងបានយកមកអភិរក្សនិងរក្សាទុកនៅសារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ។









## កម្មវិធីអប់រំផ្សព្វផ្សាយបេតិកភណ្ឌ

ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ អាជ្ញាធរជាតិព្រះវិហារបានរៀបចំវគ្គអប់រំផ្សព្វផ្សាយបេតិកភណ្ឌដល់សិស្សានុសិស្សចំនួន៦៣៨នាក់ និងដល់ប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន២៤០នាក់ ដើម្បីលើកកម្ពស់ការយល់ដឹង និងចូលរួមថែរក្សាអភិរក្សសម្បត្តិវប្បធម៌។











# ការងារកំណាយស្រាវជ្រាវ

# ការងារកំណាយស្រាវជ្រាវប្រព័ន្ធរំដោះទឹកភ្លៀង



ចាប់ពីឆ្នាំ២០១៦ដល់ឆ្នាំ២០២០ អាជ្ញាធរជាតិព្រះវិហារបានធ្វើការសិក្សាស្រាវជ្រាវនិងធ្វើកំណាយ ដើម្បីស្តាររចនាសម្ព័ន្ធប្រព័ន្ធបង្ហូរទឹកបុរាណចំនួន ៣ ទីតាំង មាន ៖ (១) សងខាងស្ពានហាលបន្ទោះគោបុរៈទី៣និងទី៤ (២) ខាងលិចស្ពានហាលបន្ទោះគោបុរៈទី៤និងទី៥ និង (៣) អមសងខាងជណ្តើរបុរាណខាងជើង។










## ការងារកំណាយស្រាវជ្រាវ និងស្តារឡើងវិញបារាយណ៍ខាងលិចនិងខាងកើត






បារាយណ៍ខាងលិចមុននិងក្រោយជួសជុលនិងស្តារឡើងវិញ



បារាយណ៍ខាងកើតមុននិងក្រោយជួសជុលនិងស្តារឡើងវិញ

## ការងារកំណាយស្រាវជ្រាវលិង្គព្រះឥសូរ



នៅឆ្នាំ២០១៧ អាជ្ញាធរជាតិព្រះវិហារ បានធ្វើកំណាយសិក្សានិងលើកបម្លាក់ លិង្គព្រះឥសូរ (២១៤ស.ម.) ដែលប្រទះឃើញនៅជាប់ខឿនជណ្តើរបុរាណ ខាងជើងផ្នែកពាយ័ព្យ និងព្រមទាំងនាំទៅសម្អាត អភិរក្សទុក និងតាំងបង្ហាញ នៅសារមន្ទីរធម្មជាតិសាកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ។









# ការងាររៀបចំផែនទីហានិភ័យ

# ការងារចងក្រងផែនទីហានិភ័យរចនាសម្ព័ន្ធប្រាសាទព្រះវិហារ

ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០២៣ អាជ្ញាធរជាតិព្រះវិហារបានសិក្សាកម្រិតហានិភ័យ នៅតួប្រាសាទព្រះវិហារ ចាប់ពីគោបុរៈទី១ ដល់ទី៥ និងស្ពានហាលខាងលិច ដើម្បីធ្វើបទអន្តរាគមន៍ទល់ទ្រឲ្យទាន់ពេលវេលា។








ប្លង់បាតស្ពានហាលខាងលិច







# ការងារអភិរក្ស

## ការងារទល់ទ្រហេដ្ឋារចនាសម្ព័ន្ធប្រាសាទព្រះវិហារ

ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០២៣ អាជ្ញាធរជាតិព្រះវិហារបានទល់ទ្រទីតាំងដែលមានហានិភ័យខ្ពស់ និងមធ្យមបានសរុប ៣០ទីតាំង មានជាអាទិ៍ ៖ (១) គោបុរៈទី១ មាន៤ទីតាំង (២) គោបុរៈទី២មាន ១១ទីតាំង (៣) គោបុរៈទី៣ មាន ៤ទីតាំង (៤) គោបុរៈទី៤មាន ៧ទីតាំង និង (៥) គោបុរៈទី៥មាន ៤ទីតាំង។









## ការងារសាងសង់ជណ្តើរនិងកម្រាលឈើ និងរៀបចំសណ្តាប់ធ្នាប់ថ្ម

ចាប់ពីឆ្នាំ២០០៨ដល់បច្ចុប្បន្ន អាជ្ញាធរជាតិព្រះវិហារបានរៀបចំជណ្តើរ និងកម្រាលឈើចំនួន១១ទីតាំង និងបានរៀបចំសណ្តាប់ធ្នាប់ថ្មចម្លាក់ដែលធ្លាក់រាយប៉ាយទៅកន្លែងមានសុវត្ថិភាពចាប់ពីគោបុរៈទី១ ដល់ទី៥នៃប្រាសាទព្រះវិហារ។













# ការងារជួសជុល

# គម្រោងជួសជុល និងអភិរក្សជណ្តើរខាងជើង

គម្រោងសហប្រតិបត្តិការអាមេរិក-កម្ពុជា

ចាប់ពីឆ្នាំ២០១៨មកទល់បច្ចុប្បន្ន សហរដ្ឋអាមេរិកតាមរយៈមូលនិធិឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកដើម្បីអភិរក្សសម្បត្តិវប្បធម៌ (AFCP) បានផ្តល់ថវិកាដើម្បីអភិរក្សនិងជួសជុលជណ្តើរខាងជើងប្រាសាទព្រះវិហារ ហើយបានទទួលលទ្ធផលដូចខាងក្រោម ៖

- បានប្រមូលបងក្រង ថតរូប សិក្សាស្ថាបត្យកម្ម និងហានិភ័យជណ្តើរទាំងមូល
- បានធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យា
- បានអភិរក្សនិងជួសជុល (១) ជណ្តើរចាប់ពីថ្នាក់ទី២ដល់ថ្នាក់ទី៩ (២) ស្ពានហាលខាងលិចប្រវែង៩ម៉ែត្រ (៣) បម្លាក់តោបំនួន៤ និងគជសីហ៍បំនួន១
- បានស្តារនិងអភិរក្សប្រព័ន្ធបង្ហូរទឹកបុរាណនៅអមសងខាងជណ្តើរ
- បានរៀបចំកម្មវិធីអប់រំនិងផ្សព្វផ្សាយដល់សិស្សានុសិស្ស និងសហគមន៍តាមមូលដ្ឋាន
- បំណែកដំណាក់កាលទី៤ ចាប់ពីថ្នាក់ទី១០ដល់ទី១៤ កំពុងបន្តដំណើរការនិងគ្រោងបញ្ចប់នៅខែធ្នូ ២០២៤ខាងមុខនេះ។




U.S. EMBASSY PHNOM PENH
Signing Ceremony
of the U.S. Ambassadors Fund for Cultural Preservation
for the Conservation and Restoration of the
Northern Ancient Staircase, Preah Vihear Temple,
Phase III (2021-2022)
h Vihear Temple, December 8, 2021







## គម្រោងជួសជុល និងអភិរក្សគោបុរៈទី៥



គម្រោងសហប្រតិបត្តិការឥណ្ឌា-កម្ពុជា



ក្នុងក្របខណ្ឌអនុស្សរណៈនៃការយោគយល់ដែលបានចុះហត្ថលេខាដោយតំណាងរដ្ឋាភិបាលឥណ្ឌា និងកម្ពុជា កាលពីឆ្នាំ២០១៨រដ្ឋាភិបាលឥណ្ឌាបានបញ្ជូនអ្នកជំនាញការជនជាតិឥណ្ឌាមកពីស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (ASI) ចាប់ផ្តើមការងារអភិរក្សនិងជួសជុលគោបុរៈទី៥ចាប់ពុងឆ្នាំ២០២២ រហូតដល់បច្ចុប្បន្ន ទទួលបានលទ្ធផលដូចខាងក្រោម ៖

- បានធ្វើកំណាយសិក្សាស្រាវជ្រាវដើម្បីយល់ពីរចនាសម្ព័ន្ធសំណង់ទូទៅនៃគោបុរៈទី៥
- កំពុងរៀបចំការដ្ឋាន និងផ្លូវវាង















# គម្រោងជួសជុលនិងអភិរក្សគោបុរៈទី១ ដល់ទី៣



គម្រោងសហប្រតិបត្តិការចិន-កម្ពុជា

ចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២៣ បណ្ឌិតសភាបេតិកភណ្ឌវប្បធម៌ចិនបានបញ្ជូនអ្នកជំនាញមកសិក្សា ដើម្បីរៀបចំផែនការអភិរក្ស និងជួសជុលគោបុរៈទី១ ទី២ និងទី៣នៃប្រាសាទព្រះវិហារ។










## ការងារជួសជុល និងអភិរក្សស្ពានហាល បង្គោលផ្កាឈូក និងបង្កាន់ដៃនាគ

ចាប់តាំងពីឆ្នាំ២០២១០ដល់បច្ចុប្បន្ន អាជ្ញាធរជាតិព្រះវិហារបានអភិរក្ស និងជួសជុល (១) ស្ពានហាលបន្ទោះគោបុរៈទី២ និងទី៣ ដោយបានស្តារដីចាក់បង្គរ បានជួសជុល បង្កាន់ដៃនាគ បានជួសជុលខឿនស្ពានហាលនៅជ្រុងខាងលិចនិងខាងកើត បានជួសជុលបង្គោលផ្កាឈូកចំនួន ៥បង្គោល និង ស្ពានហាលបន្ទោះគោបុរៈទី៤ និងទី៥ បានជួសជុលបង្គោលផ្កាឈូកចំនួន ៥៦បង្គោល។











## វគ្គបណ្តុះបណ្តាលជំនាញអភិរក្ស និងជួសជុលវត្ថុបុរាណ



អាជ្ញាធរជាតិព្រះវិហារបានសហការជាមួយអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិសំបូរព្រៃគុក និងស្ថាប័នអន្តរជាតិមួយចំនួនបណ្តុះបណ្តាលមន្ត្រីនិងបុគ្គលិក លើជំនាញ បុរាណវិទ្យា អភិរក្សនិងជួសជុលវត្ថុសិល្បៈ អភិរក្សនិងជួសជុលប្រាសាទឥដ្ឋ ការគ្រប់គ្រងសារមន្ទីរ ការគ្រប់គ្រងទេសចរ និងការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន។







# ការងារបរិស្ថាន និងព្រៃឈើ

# ការងារអភិរក្ស និងស្តារគម្របព្រៃឈើឡើងវិញនៅតំបន់ប្រាសាទព្រះវិហារ

អាជ្ញាធរជាតិព្រះវិហារបានស្តារ និងអភិរក្សគម្របព្រៃឈើឡើងវិញនៅទីតាំងរេបរិលជាង ៥០ហិកតា ក្នុងតំបន់ការពារទី២ សរុបចំនួនកូនឈើ ២៦ប្រភេទ ស្មើនឹង ៨១៩៩៦ដើម និងព្រមទាំងបានរៀបចំថ្នាលបណ្តុះកូនឈើបាន៤១ប្រភេទ ស្មើនឹង ៩៤៥៩១ កូន។











ការងាររៀបចំថ្នាលបណ្ដុះកូនឈើ កាត់ដកហ្មួតដើមឈើ និងកាត់ក្រីមែកឈើ














# ការងារអភិវឌ្ឍន៍សហគមន៍

## ការងារបណ្តុះបណ្តាលបច្ចេកទេស និងបង្កើនសមត្ថភាពកសិករគំរូ

ក្រុមការងារសហគមន៍អាជ្ញាធរជាតិព្រះវិហារបានផ្តល់ជូនទៅប្រជាសហគមន៍នូវ (១) បច្ចេកទេសចិញ្ចឹមត្រីចំនួន៨វគ្គ (២) បច្ចេកទេសផលិតជីកំប៉ុស្តិ៍ទឹក និងជីកំប៉ុស្តិ៍គោកចំនួន៤វគ្គ (៣) បច្ចេកទេសកាត់ផ្សាំមែកដំណាំឈើហូបផ្លែចំនួន២វគ្គ (៤) បច្ចេកទេសដាំឈើហូបផ្លែ និងថែទាំពីកត្តាចង្រៃផ្សេងៗចំនួន២វគ្គ (៥) បច្ចេកទេសដាំបន្លែសុវត្ថិភាពចំនួន២វគ្គ (៦) បច្ចេកទេសធ្វើកសិកម្មចម្រុះចំនួន១វគ្គ (៧) បច្ចេកទេសគ្រប់គ្រងបម្ការ និងប្រព័ន្ធស្រោចស្រពដំណាំចំនួន១វគ្គ និង(៨) បច្ចេកទេសផ្សាំមែកផ្កាក្រដាស់ចំនួន១វគ្គ ដែលក្នុងមួយវគ្គៗមានកសិករចូលរួមជាមធ្យមចំនួន៣០នាក់។











# ការងាររៀបចំកសិដ្ឋានចិញ្ចឹមត្រីទីឡាព្យា

ចាប់តាំងពីឆ្នាំ២០១៧មក អាជ្ញាធរជាតិព្រះវិហារបានចូលរួមពីដៃគូរក្រុមហ៊ុនអភិវឌ្ឍន៍របស់ប្រទេសជប៉ុនក្នុងការអភិវឌ្ឍន៍សហគមន៍ ក្នុងនោះរៀបចំកសិដ្ឋានចិញ្ចឹមត្រី និងផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសប្រជាកសិករ (៨០គ្រួសារ)។ កសិដ្ឋាននេះមានអាងភ្ញាស់កូនត្រី (១អាង) ស្រះធំៗ (១០ស្រះ) និងរៀបចំចិញ្ចឹមមេពូជត្រីទីឡាព្យា និងត្រីអណ្តែង សម្រាប់ភ្ញាស់កូន និងចែកជូនកសិករ។










## ការងារលើកកម្ពស់សុវត្ថិភាពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ

មកទល់ពេលនេះ អាជ្ញាធរជាតិព្រះវិហារបានផ្តល់អណ្តូងស្នប់ដល់ប្រជាជនក្រីក្រចំនួន៩៦ និងបានជួសជុលអណ្តូងស្នប់ចំនួន៥០ និងបានសហការជាមួយដៃគូអភិវឌ្ឍន៍ជីកស្រះទឹកសហគមន៍ចំនួន ៣ស្រះ (ទំហំ៤០ម៉ែត្រ x ៥០ម៉ែត្រ និងជម្រៅ៣ម៉ែត្រ) និងបានបំពាក់នូវប្រព័ន្ធសូឡាបូមទឹក និងប្រព័ន្ធចែកចាយទឹកដល់ផ្ទះកសិករចំនួន២១គ្រួសារក្នុងភូមិធម្មជាតិតេជោ ហ៊ុន សែន ព្រះវិហារ។













## ការងារសួនបន្លែសរីរាង្គភូមិធម្មជាតិសម្តេចតេជោរបស់អាជ្ញាធរជាតិព្រះវិហារ

ក្រុមការងារបានពិសោធមន៍ការបិញ្ចឹមសត្វ ដូចជា មាន់ ទា ក្ងាន និងជ្រូកព្រៃ ការសាកល្បងដាំស្រូវពូជថ្មីៗ ការដាំបន្លែពូជនាំចូលនិងពូជក្នុងស្រុកក្នុងផ្ទះសំណាញ់របស់ខ្លួន។ ក្នុងនោះ ក្រុមការងារក៏បានបង្ហាត់បង្រៀននិងចែកពូជដំណាំ និងសត្វធាតុមួយចំនួនដល់សហគមន៍ និងសិស្សតាមសាលា ដើម្បីយកទៅអនុវត្តនៅតាមផ្ទះ និងសាលារៀនរបស់ពួកគេជាប្រចាំ។















# ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ

# សារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ

សារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ បានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨។ សារមន្ទីរធម្មជាតិសកលនេះមានគោលបំណងបង្ហាញនូវពត៌មានប្រវត្តិសាស្ត្រទូទៅ ពិសេសពាក់ព័ន្ធរមណីយដ្ឋានប្រាសាទព្រះវិហារដូចជា បម្លាក់បដិមា វត្ថុសិល្បៈ នរវិទ្យា បុរាណវិទ្យា ទំនៀមវប្បធម៌ជនជាតិដើមភាគតិចកួយ សត្វ និងរុក្ខជាតិ ដើម្បីជាប្រយោជន៍ ចំពោះការសិក្សាស្រាវជ្រាវ ការអប់រំ ព្រមទាំងការផ្សព្វផ្សាយ។ សមុច្ច័យក្នុងសារមន្ទីរមានវត្ថុសិល្បៈចំនួន២៤០ ដែលធ្វើអំពីថ្មភក់ លោហធាតុ ឈើ កុលាលភាជន៍ ឫស្សី សំណាករុក្ខជាតិ សត្វ និងឆ្អឹង។



# ការងាររៀបចំស្ថាបនាមណ្ឌលអគារបដិសណ្ឋាកិច្ចប្រាសាទព្រះវិហារ

នៅឆ្នាំ២០២១ អាជ្ញាធរជាតិព្រះវិហារបានចាប់ផ្ដើមស្ថាបនានិងរៀបចំមណ្ឌលអគារបដិសណ្ឋាកិច្ចប្រចាំរមណីយដ្ឋានប្រាសាទព្រះវិហារ ដើម្បីរៀបចំសណ្ដាប់ធ្នាប់សេវាទេសចរណ៍ និងផ្ដល់សេវាកម្មផ្សេងៗដល់ភ្ញៀវទេសចរមកទស្សនារមណីយដ្ឋានប្រាសាទព្រះវិហារនេះឲ្យកាន់តែប្រសើរ និងមានពត៌មានស្ដីពីរមណីយដ្ឋានគ្រប់គ្រាន់។ គម្រោងនេះមានស្ថាបនាអគារលក់សំបុត្រ អគារបកស្រាយពត៌មាន អគាររង់ចាំនិងចំណតរថយន្ត អគារបន្ទប់ទឹកសាធារណៈ និងអគាររង់ចាំដឹកភ្ញៀវទេសចររបស់សហគមន៍ជាដើម។







## ការងាររៀបចំស្ថាបនាផ្លូវបេតុងលើភ្នំប្រាសាទព្រះវិហារ

នៅឆ្នាំ២០១១ ផ្លូវបេតុងថ្មីមួយខ្សែបានស្ថាបនាភ្ជាប់ពីជើងភ្នំរហូតដល់មុខវត្តកែវសិក្ខាគីរីស្វារៈលើភ្នំប្រាសាទព្រះវិហារ។ រហូតដល់ឆ្នាំ២០២១ អាជ្ញាធរជាតិព្រះវិហារបានស្ថាបនាកំណាត់ផ្លូវបេតុងថ្មីបន្តប្រវែងសរុប ៣៣៥ម៉ែត្រ និងផ្លូវថ្មើរជើងមួយខ្សែតភ្ជាប់ទៅស្ពានហាលខាងលិចនៃប្រាសាទ ចាប់ពីមុខវត្តកែវសិក្ខាគីរីស្វារៈទៅដល់ទួលបុរាណ និងប៉ុស្តិ៍ផែកសំបុត្រលើភ្នំប្រាសាទព្រះវិហារ ដើម្បីបង្កភាពងាយស្រួលបន្ថែមមួយកម្រិតទៅជូនដល់ភ្ញៀវទេសចរ។



# ការងាររៀបចំស្ដាបនាជណ្ដើរឈើអមជណ្ដើរបុរាណខាងកើតភ្នំប្រាសាទព្រះវិហារ

នៅឆ្នាំ២០០៩-២០១០ ក្រោមកិច្ចសហការជាមួយអាជ្ញាធរជាតិព្រះវិហារ និងក្រុមការងារពិសេសថ្នាក់ជាតិបានរៀបចំស្ដាបនាជណ្ដើរឈើអមជណ្ដើរបុរាណខាងកើតប្រវែង១៥០០ម៉ែត្រ ចាប់ជាជើងភ្នំស្របតាមជណ្ដើរបុរាណខាងកើតឡើងទៅដល់គោបុរៈទី៥នៃប្រាសាទព្រះវិហារ ក្នុងនោះជណ្ដើរឈើមានកាំជណ្ដើរចំនួន ២២៤២កាំនិង១៩១ថាស និងសាលាសំណាក់ចំនួន៥ទីតាំងនៅអមជណ្ដើរនេះ។





អាជ្ញាធរជាតិព្រះវិហារ

National Authority for Preah Vihear

2023